# យោបល់រួម ១៣ (១៩៩៩)

# សិទ្ធទទួលការអប់រំ

## (មាត្រា ១៣ ស្តីពីកិច្ចព្រមព្រៀងអន្តរជាតិលើសិទ្ធផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌)

១- ការអប់រំ គឺជាសិទ្ធមនុស្សផង និងជាមធ្យោបាយមួយចាំបាច់ក្នុងការធ្វើឱ្យសំរេចសិទ្ធមនុស្សដ៏ទៃទៀត ។ ដើម្បីធ្វើការពង្រឹងនូវសិទ្ធ ការអប់រំគឺជាយានដ៏ចំបងដែលមនុស្សពេញវ័យ និងកុមារអាចដកខ្លួនផុតពីភាពក្រីក្រដែលក្បៀបសង្កត់ដោយសេដ្ឋកិច្ច និងសង្គម ហើយនឹងទទួលបាននូវមធ្យោបាយដើម្បីគេចូលរួមពេញលេញទៅក្នុងសហគន៏របស់គេ ។ ការអប់រំមានតួនាទីសំខាន់ក្នុងការផ្តល់អំណាចដល់ស្ត្រី , ការការពារសុវត្ថិភាពកុមារពីការធ្វើអាជីវកម្ម និងពីការធ្វើការងារហួសកំណត់ហើយនិងអាជីវកម្មផ្លូវភេទ , ពង្រឹងសិទ្ធមនុស្សនិងប្រជាធិបតេយ្យ,ការពារបរិស្ថាន និងត្រួតពិនិត្យមើលលើការរីកចំរើននៃពលរដ្ឋ ។ លើសពីនេះទៀត, ការអប់រំត្រូវគេទទួលស្គាល់ថាជាការវិនិយោគទុនដ៏ប្រសើរសំរាប់ប្រទេសជាតិ ប៉ុន្តែសារប្រយោជន៏នៃការអប់រំ ពុំមែនស្ថិតត្រឹមតែជាការអនុវត្តន៏ជាក់ស្តែងនិងមធ្យោបាយប្រើប្រាស់ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការស្តុកទុកមួយដ៏ល្អ ជាពន្លឺខួរក្បាលដ៏សកម្មមួយ ដែលអាចរក្សាទុកដោយសេរីនិងដ៏ទូលំទូលាយផងដែរ ហើយនិងគឺជាភាពរីករាយមួយ និងជារង្វាន់នៃសារធាតុរបស់មនុស្ស ។

២- កិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធលើផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) បានបង្កើតចេញជាពីរមាត្រាអំពីសិទ្ធិទទួលការសិក្សាអប់រំ គឺមាត្រាទី១៣និង១៤ ។ មាត្រា១៣គឺជាប្រការវែងជាងគេនៅក្នុងកិច្ចព្រមព្រៀងនេះដែលមានការរៀបរាប់ដ៏ទូលំទូលាយ និងដ៏សំខាន់នូវប្រការស្តីពីសិទ្ធិទទួលការសិក្សាអប់រំដែលមាននៅ ក្នុងច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ។ គណៈកម្មាធិការបានសំរេចរួចហើយនូវយោបល់ទូទៅទី១១ នៅក្នុង មាត្រា១៤ (ផែនការសកម្មភាពចំពោះការអប់រំចំបង) ។ យោបល់ទូទៅទី១១ ហើយនិងយោបល់ទូទៅ បច្ចុប្បន្ននេះគឺសំរាប់បំពេញបន្ថែមហើយនិងសំរាប់ធ្វើការពិចារណារួមគ្នា ។ គណៈកម្មាធិការបានដឹងថា មនុស្សរាប់លាននាក់ក្នុងពិភពលោកយល់ថាទិសដៅនៃការទទួលនូវសិទ្ធិអំរំនេះស្ថិតនៅឆ្ងាយពីខ្លួនគេនៅឡើយ ។ លើសពីនេះទៅទៀត, មាននៅក្នុងករណីជាច្រើនទិសដៅនេះកំពុងកាន់តែដាច់ស្រយាលឡើងៗ ។ គណៈកម្មាធិការកំពុងចាប់អារម្មណ៏ផងដែរ នូវរចនាសម្ព័ន្ធដ៏គួរឱ្យខ្លាចរអែង ហើយនឹងឧបសគ្គដទៃទៀតដែលរាំងស្ទះដល់ការធ្វើឱ្យសំរេចពេញលេញនូវមាត្រា១៣ នៅក្នុងរដ្ឋដែលជាភាគីនៃកិច្ចព្រមព្រៀងនេះ។

៣- ក្នុងទស្សនៈវិស័យជួយដល់រដ្ឋភាគីទាំងឡាយក្នុងការអនុវត្តនូវកិច្ចព្រមព្រៀង និងក្នុងការបំពេញកាតព្វកិច្ចធ្វើរបាយការណ៏របស់ខ្លួន យោបល់ទូទៅនេះបានផ្តោតទៅលើមាតិកាធម្មតានៃមាត្រា ១៣ (ផ្នែកទីI, វាក្យខ័ណ្ឌ ៤-៤២) ដែលកាតព្វកិច្ចខ្លះកើតឡើងពីយោបល់ទូទៅនេះ (ផ្នែកទីII, វាក្យខណ្ឌ ៤៣-៤៧) ហើយនឹងការរំលោភដូចមានបង្ហាញក្នុងរូបភាពស្រាប់ (ផ្នែកទីII ,វាក្យខ័ណ្ឌ ៥៨-៥៩) ។ នៅក្នុងផ្នែកទី៣ បានធ្វើការកត់សំគាល់ខ្លីៗ អំពីកាតព្វកិច្ចនៃអ្នកសំដែងជាជាង

អំពីរដ្ឋជាភាគី ។ យោបល់ទូទៅនេះបានផ្អែកលើបទពិសោធន៍របស់គណៈកម្មាធិការក្នុងការពិនិត្យរបាយការណ៍របស់រដ្ឋភាគីដែលមានមកជាច្រើនឆ្នាំមកហើយ ។

## I- មាតិកាគោលនៃមាត្រា ១៣

## មាត្រា១៣ (១) : គោលបំណង និងកម្មវត្ថុនៃការសិក្សាអប់រំ

៤- រដ្ឋភាគីព្រមព្រៀងថា រាល់ការអប់រំ ទោះសធារណៈឬឯកជន ផ្លូវការឬមិនផ្លូវការត្រូវតែនាំឆ្ពោះទៅរកគោលបំណង និងកម្មវត្ថុដូចបានធ្វើអត្តសញ្ញាណក្នុងមាត្រា ១៣(១) ។ គណៈកម្មាធិការកត់សំគាល់ថា កម្មវត្ថុអប់រំនេះឆ្លុះបញ្ចាំងនូវបំណងនិងគោលការណ៍សំខាន់ៗរបស់អង្គការសហប្រជាជាតិ ដូចមានចែងក្នុងមាត្រា ២៦(២) នៃសេចក្តីប្រកាសសកលពីសិទ្ធិមនុស្ស ប៉ុន្តែមាត្រា១៣(១) បន្ថែមទៅលើសេចក្តីប្រកាសនេះនូវគោលគំនិតបីគឺ :

- ការអប់រំត្រូវតែដឹកនាំទៅរកបុគ្គលិកលក្ខណៈនៃ" ភាពថ្លៃថ្នូរ"
- ការអប់រំត្រូវផ្តល់លទ្ធភាពឱ្យជនទូទៅទាំងឡាយឱ្យចូលរួមដ៏មានប្រសិទ្ធភាពនៅក្នុងសង្គមសេរី
- ហើយការ អប់រំនេះជំរុញឱ្យមានការយល់ដឹងក្នុងចំណោមក្រុមជាតិពន្ធទាំងអស់ រួមទាំងប្រជាជាតិទាំង អស់ ទោះពូជសាសន៍និងសាសនាអ្វីក្តី។

ចំពោះកម្មវត្ថុនៃការអប់រំដែលរួមមាននៅក្នុងមាត្រា២៦(២) នៃសេចក្តីថ្លែងការណ៍សកលពីសិទ្ធិមនុស្ស និងមាត្រា ១៣(១) នៃកិច្ចព្រមព្រៀង ប្រហែលជាអ្វីដែលមានសារសំខាន់នោះគឺ "ការអប់រំត្រូវនាំឆ្ពោះទៅរកការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈមនុស្ស" ។

៥- គណៈកម្មាធិការកត់សំគាល់ថា ចាប់ពីមហាសន្និបាតអង្គការសហប្រជាជាតិបានសំរេចនូវកិច្ចព្រមព្រៀងឆ្នាំ ១៩៦៦ មក ឯកសារអន្តរជាតិដទៃទៀតបានតាក់តែងបន្ថែមទៀតនូវកម្មវត្ថុដែលធ្វើឱ្យការអប់រំមានដំណើរការទៅមុខបាន ។ ទន្ទឹមនឹងនេះ គណៈកម្មាធិការបានពនិត្យឃើញថា រដ្ឋភាគីទាំងឡាយត្រូវបានតំរូវឱ្យធានា នូវការអប់រំឱ្យស្របតាមគោលបំណង និងកម្មវត្ថុដូចបានកំណត់ក្នុងមាត្រា១៣(១) ដូចបានបកស្រាយដើម្បី ជាការបំភ្លឺចំពោះសេចក្តីថ្លែងការពិភពលោកលើការអប់រំជាទូទៅ (Jomtien, 1990) (មាត្រា១) អនុសញ្ញាស្តីពីសិទ្ធិកុមារ (មាត្រា២៩ [១]) សេចក្តីថ្លែងការណ៍ទីក្រុងវីយែន និងកម្មវិធីសកម្មភាព (វាក្យខ័ណ្ឌ ៣៣ និង ៨០ ) និងផែនការណ៍សកម្មភាពសំរាប់អង្គការសហប្រជាជាតិដប់ឆ្នាំនៃសិទ្ធិមនុស្ស (វាក្យខ័ណ្ឌ២) ។ នៅពេលដែលអត្ថបទទាំងនោះទំនាក់ទំនងជិតដិតទៅនឹងមាត្រា១៣(១)នៃកិច្ចព្រមព្រៀង ក្នុងអត្ថបទនោះមានចែងអំពីអង្គធាតុដែលមាត្រា ១៣ (១)ពុំបានចែងច្បាស់លាស់ ដូចជាលិខិតយោង ពិសេសទៅនឹងភាពស្មើគ្នានៃភេទ និងការគោរពនូវបរិស្ថានជាដើម ។ អង្គធាតុថ្មីនេះមានបញ្ជាក់ច្បាស់លាស់ហើយឆ្លុះបញ្ចាំងនូវការបកស្រាយទំនើបអំពីមាត្រា១៣(១)នេះ ។ គណៈកម្មាធិការទទួល

នូវការគាំទ្រលើទស្សនៈនេះ អំពីការទទួលស្គាល់ដ៏ធំធេងថា អត្ថបទដែលបានចែងពីមុនមកបានទទួលពីគ្រប់ភូមិភាគទាំងអស់ក្នុង ពិភពលោក ។

## មាត្រា១៣ (២) : សិទ្ធិទទួលនូវការសិក្សាអប់រំ ការសំគាល់នូវនៅខ្លះៗ

៦- នៅពេលអនុវត្តដ៏ច្បាស់លាស់ និងសមស្របនូវពាក្យពេចន៍ទាំងនោះ ត្រូវផ្អែកទៅលើល័ក្ខខ័ណ្ឌលើសលប់នៃរដ្ឋភាគីដោយឡែកមួយ ការអប់រំនូវរាល់ទំរង់របស់គេនិងគ្រប់កំរិតត្រូវតែបង្ហាញអំពីអន្តរៈទំនាក់ទំនង និងទ្រង់ទ្រាយសំខាន់ដូចតទៅនេះ :

**ក- *ភាពមានថ្នាក់រៀន*-**ការប្រព្រឹត្តទៅនៃស្ថាប័ន និងកម្មវិធីអប់រំត្រូវតែមានត្រៀមក្នុងចំនួនគ្រប់គ្រាន់នៅក្នុងយុត្តាធិការនៃរដ្ឋភាគី ។ អ្វីដែលរដ្ឋភាគីត្រូវការដើម្បីប្រព្រឹត្តទៅគឺស្ថិតនៅលើកត្តាជាច្រើន រួមមានកត្តាអភិវឌ្ឍន៏ខ្លឹមសារដែលគេកំពុងប្រតិបត្តិការ ឧទាហរណ៏ : រាល់ស្ថាប័ននិងកម្មវិធីដូចជាការត្រូវការនូវអាគារ ឬ ការការពារដទៃទៀតពីអង្គធាតុ ឧបករណ៏អនាម័យសំរាប់ភេទទាំងពីរ ទឹកអនាម័យ គ្រូបណ្ដុះបណ្ដាលក្នុងស្រុកដែលមានប្រៀវត្សន៏សមស្រប, ឧបករណ៏បង្រៀន ។ល។ នៅពេលខ្លះកម្មវិធីនឹងត្រូវការផងដែរនូវការឧបត្ថម្ភដូចជា បណ្ណាល័យ, កុំព្យូទ័រ, មន្ទីរពិសោធន៏ និងពត៌មានវិទ្យា ។

**ខ- *ការចូលសិក្សាបាន*-**ស្ថាប័ន និងកម្មវិធីអប់រំត្រូវតែបានអនុញ្ញាតឱ្យចូលរៀនសូត្របានដល់សាធារណជនទាំងអស់ដោយគ្មានការរើសអើងនៅក្នុងយុត្តាធិការនៃរដ្ឋភាគី ។ ការអាចចូលសិក្សាបានមានទំហំត្រួតគ្នាជាបីគឺ :

**ការមិនរើសអើង-** ការអប់រំត្រូវបើកឱ្យមានដល់ជនគ្រប់រូប ពិសេសជនដែលមានស្ថានភាពក្រីក្រជាងគេ, តាមអង្គច្បាប់និងអង្គហេតុ , ដោយគ្មានការរើសអើងដល់គ្រប់មូលដ្ឋានដែលត្រូវហាមឃាត់ ( សូមអាន វាក្យខ័ណ្ឌ ៣១-៣៧អំពីការមិនរើសអើង ) ។

**ការចូលសិក្សាបានទាំងរូបរាងកាយ-**ការអប់រំត្រូវតែធ្វើក្នុងទំរង់សុវត្ថិភាពនៃរូបរាងកាយ ទាំងខាងការចូលរួមក្នុងរង្វង់ទីតាំងភូមិសាស្ត្រសមស្រប ឧទាហរណ៏សាលាដែលនៅជិតខាង ឬ ឆ្លងកាត់តាមបច្ចេកវិទ្យាទំនើប (ឧទាហរណ៏ អាចចូលរៀនក្នុងកម្មវិធីពីចំងាយជាដើម) ។

**ការចូលរៀនបានក្នុងផ្នែកសេដ្ឋកិច្ច-** ការអប់រំត្រូវតែអាចមានលទ្ធភាពដល់ជនគ្រប់រូបដែលអាចបង់ថ្លៃបាន ។ ទំហំនៃការចូលរៀននេះ ស្ថិតនៅក្រោមប្រការចែងនៃមាត្រា ១៣(២) ចំពោះការរៀននៅសាលាបឋមសិក្សា

មធ្យមសិក្សា និងឧត្តមសិក្សា ដោយហេតុថា ការសិក្សានៅបឋមសិក្សា ត្រូវតែ "ឥតបង់ថ្លៃដល់ជនគ្រប់រូប" ។ រដ្ឋភាគី ត្រូវបានតម្រូវដោយមិនគិតថ្លៃចំពោះសាលា បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សាទៀតផង ។

គ- **<u>ភាពអាចទទួលយកបាន</u>-** បែបបទ និងសារធាតុនៃការអប់រំ រួមមានកម្មវិធីសិក្សា និងវិធីបង្រៀន ត្រូវតែអាចទទួលយកបាន (ឧទាហរណ៍ ត្រូវតែពាក់ព័ន្ធនឹងវប្បធម៌ដ៏ត្រឹមត្រូវ និងមានគុណភាពល្អ) ដល់សិស្ស និងក្នុងករណីសមស្រប, មាតាបិតា, ទាំងនេះ ត្រូវស្ថិតក្រោមកម្មវត្ថុនៃការសិក្សា ដែលបានចែងដោយមាត្រា ១៣(១) ហើយ ស្តង់ដារអប់រំជាអប្បបរិមាដូចនេះ ត្រូវតែមានការអនុម័តដោយរដ្ឋនិមួយៗ (សូមអានមាត្រា ១៣(៣) និង (៤) ។

ឃ- **<u>ភាពអាចសំរបសំរួលបាន</u>-** ការអប់រំត្រូវតែប្រែប្រួលទៅតាមកាលៈទេសៈ ហើយអាចនឹងសម្របទៅតាមការចាំបាច់នៃការផ្លាស់ប្តូរសង្គម និងសហគមន៍ ហើយត្រូវឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សិស្ស ក្នុងរង្វង់ស្ថានភាពផ្សេងៗពីគ្នានៃសង្គម និងវប្បធម៌ ។

៧- នៅពេលពិចារណាលើការអនុវត្តន៍ដ៏ត្រឹមត្រូវនូវទ្រង់ទ្រាយសំខាន់ៗ និងអន្តរៈទំនាក់ទំនងទាំងនេះ គឺថាផលប្រយោជន៍ដ៏ប្រសើររបស់សិស្ស ត្រូវតែធ្វើការពិចារណាឱ្យបានច្បាស់លាស់ ។

## មាត្រា ១៣ (២) ក : សិទ្ធិទទួលការសិក្សាថ្នាក់បឋមសិក្សា

៨- ការអប់រំផ្នែកបឋមសិក្សា រួមមានអង្គធាតុនៃភាពមានថ្នាក់សិក្សា អាចចូលរៀនបាន ភាពអាចទទួលយកបាន និងភាពអាចសម្របសម្រួលបាន ដែលជាអង្គធាតុរួមនៃការអប់រំ ចំពោះរាល់បែបផែន និងគ្រប់កំរិត ។

៩- គណៈកម្មាធិការត្រូវទទួលនូវការណែនាំពីការបកស្រាយដ៏សមស្របលើពាក្យថា "ការអប់រំផ្នែកបឋមសិក្សា" នេះពីសេចក្តីថ្លែងសកលស្តីពីការសិក្សាដល់ជនទូទៅ ដែលក្នុងនេះបានចែងថា : "ការផ្តល់នូវប្រព័ន្ធសំខាន់សំរាប់ការអប់រំមូលដ្ឋានដល់កុមារា-កុមារី ផ្នែកខាងក្រៅពីគ្រួសារ គឺជាការរៀនសូត្រដ៏ចំបង ។ ការអប់រំផ្នែកបឋមសិក្សានេះ ត្រូវតែជាសកល និងត្រូវធានាថា មូលដ្ឋានចាំបាច់ក្នុងការរៀនសូត្ររបស់កុមារា-កុមារីនេះ ត្រូវតែទទួលនូវការពេញចិត្ត ហើយត្រូវគិតគូរអំពីវប្បធម៌ សេចក្តីត្រូវការ និងឱកាសរបស់សហគមន៍ផង (មាត្រា ៥) ។ "មូលដ្ឋានចាំបាច់ក្នុងការរៀនសូត្រមានចែងជានិយមន័យក្នុងមាត្រា ១ នៃសេចក្តីថ្លែងការសកល" ។ ពេលដែលការសិក្សាផ្នែកបឋមសិក្សា មិនមានន័យត្រូវគ្នា នឹងពាក្យមូលដ្ឋានអប់រំក្តី ប៉ុន្តែវាមានន័យស្រដៀងគ្នារវាងពាក្យទាំងពីរ ។ ក្នុងករណីនេះ គណៈកម្មការបានឯកភាពយកនូវជំហរដែលទទួលយកដោយ UNICEF : "ការអប់រំផ្នែកបឋមសិក្សា គឺជាសមាសភាគដ៏សំខាន់បំផុតនៃការអប់រំមូលដ្ឋាន" ។

១០- ដូចមានចែងក្នុងមាត្រា ១៣ (២) ក ការអប់រំជាមូលដ្ឋាន មានទ្រង់ទ្រាយពីរខុសគ្នា គឺជាការអប់រំមួយ "ដាច់ខាត" ហើយ "ត្រូវតែមានដោយឥតគិតថ្លៃជាទូទៅ" ។ ចំពោះការពិនិត្យរបស់គណៈកម្មាធិការ ទៅលើពាក្យទាំងពីរនេះ សូមអានថាវាក្យខ័ណ្ឌ ៦ និង ៧ នៃយោបល់ទូទៅ លេខ ១១ នៃមាត្រា ១៤ របស់កិច្ចព្រមព្រៀង ។

## មាត្រា ១៣(២) ខ : សិទ្ធិទទួលការសិក្សាអប់រំផ្នែកមធ្យមសិក្សា

១១- ការសិក្សា-អប់រំផ្នែកមធ្យមសិក្សា មានអង្គធាតុដូចជា ការមានថ្នាក់សិក្សា ការអាចចូលរៀនសូត្របាន ការទទួលយកបាន និងការអាចសម្របសម្រួលបាន ដែលត្រូវតែទូទៅសំរាប់ការសិក្សាទាំងអស់ក្នុងបែបផែន និងគ្រប់កំរិត ។

១២- ពេលដែលមាតិកានៃការសិក្សាផ្នែកមធ្យមសិក្សា អាចនឹងខុសគ្នារវាងរដ្ឋភាគី ហើយពេលក្រោយទៀត ក៏មានការបំពេញនូវការអប់រំជាមូលដ្ឋាន និងការពង្រឹងនូវគ្រឹះនៃជីវិតនៃការរៀនសូត្រដ៏យូរអង្វែង និងការអភិវឌ្ឍន៍មនុស្សផង ។ ការសិក្សានេះ គឺត្រៀមសិស្សឱ្យមានជំនាញការងារ និងបន្តការសិក្សាជាន់ខ្ពស់បើគេមានឱកាស ។ មាត្រា ១៣(២) ខនេះ អនុវត្តចំពោះការអប់រំផ្នែកមធ្យមសិក្សា "ក្នុងបែបផែនផ្សេងៗពីគ្នា" ដែលគេទទួលស្គាល់ថា ការអប់រំផ្នែកមធ្យមសិក្សាទាមទារនូវកម្មវិធីប្រែប្រួលតាមកាលៈទេសៈ និងការផ្តល់ប្រព័ន្ធប្លែកៗ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សិស្ស នៅក្នុងមជ្ឈដ្ឋានសង្គម និងវប្បធម៌ ។ គណៈកម្មាធិការលើកទឹកចិត្ត "ជម្រើស" កម្មវិធីសិក្សា ដែលសមគ្នាទៅនឹងប្រព័ន្ធមធ្យមសិក្សាធម្មតា ។

១៣- ស្របតាមមាត្រា ១៣ (២) ខ ថ្នាក់អប់រំមធ្យមសិក្សា ជាទូទៅ "ត្រូវតែធ្វើឡើងអោយមានថ្នាក់ និងអាចចូលរៀនបានដល់ជនទូទៅ តាមគ្រប់មធ្យោបាយសមស្រប ហើយដោយឡែកត្រូវតែបង្កអោយមានការសិក្សាដោយឥតគិតថ្លៃ" ។ "ឃ្លាថា ជាទូទៅត្រូវឱ្យមានថ្នាក់ទទួល" មានន័យថា ទី ១ ការសិក្សាផ្នែកមធ្យមសិក្សា គឺ មិនពឹងផ្អែកលើសមត្ថភាពខាងក្រៅរបស់សិស្ស ឬ លទ្ធភាពទេ , ទី២ ការសិក្សាផ្នែកមធ្យមសិក្សា ត្រូវតែចែកចាយទូទាំងប្រទេស ក្នុងមធ្យោបាយមួយដែលជនគ្រប់រូបអាចទទួលបានដូចៗគ្នា ។ ចំពោះការបកស្រាយរបស់គណៈកម្មាធិការនូវពាក្យ " អាចចូលរៀនបាន" សូមអានវាក្យខ័ន្ឌ ៦ ខាងលើ ។ ឃ្លាថា "តាមមធ្យោបាយសមស្រប" គឺ ដើម្បីពង្រឹងចំនុចថា រដ្ឋភាគីគួរជ្រើសរើសមធ្យោបាយប្លែកៗ និង គំនិតថ្មីៗចំពោះការផ្តល់នូវការសិក្សាផ្នែកមធ្យមសិក្សានេះក្នុងខ្លឹមសារសង្គម និងវប្បធម៌ផ្សេងៗ ។

១៤- ការបញ្ចូលជាលំដាប់នូវការសិក្សាឥតគិតថ្លៃ មានន័យថា ពេលដែលរដ្ឋត្រូវតែឱ្យអាទិភាពដល់ការផ្តល់នូវការសិក្សាផ្នែកបឋមសិក្សាឥតគិតថ្លៃ រដ្ឋក៏មានកាតព្វកិច្ចប្រើនូវជំហ៊ានជាក់ស្តែង ឆ្ពោះទៅសម្រេចការផ្តល់ការសិក្សាទាំងមធ្យម

សិក្សា និងឧត្តមសិក្សាដោយឥតគិតថ្លៃដែរ ។ ចំពោះការសង្កេតឃើញជាទូទៅរបស់គណៈកម្មាធិការ ទៅលើន័យរបស់ពាក្យ "ឥតគិតថ្លៃ" សូមអានវាក្យខ័ណ្ឌ ៧ នៃយោបល់ទូទៅលេខ ១១ , មាត្រា ១៤ ។

## ការសិក្សាផ្នែកបច្ចេកទេស និងវិជ្ជាជីវៈ

១៥- ការសិក្សាផ្នែកបច្ចេកទេស និងវិជ្ជាជីវៈ (TVE) បង្កើតជាចំណែកនៃសិទ្ធិពីរ ទទួលការសិក្សាអប់រំ និងសិទ្ធិការងារ (មាត្រា ៦ (២) ។ មាត្រា ១៣(២) ខ បង្ហាញអំពី TVE ជាចំណែកនៃការអប់រំផ្នែកមធ្យមសិក្សា ដែលឆ្លុះបញ្ចាំងពីសារវន្ត ដោយឡែកពី TVE ក្នុងកំរិតនៃការសិក្សាអប់រំ ។ ទោះដូចម្តេចក្តី មាត្រា ៦(២) ពុំបានយោង ទៅ TVE ក្នុងទំនាក់ទំនងទៅលើកំរិតដោយឡែកនៃការសិក្សាអប់រំ ដោយគេយល់ថា TVE មានតួនាទីទូលំទូលាយក្នុងការជួយដល់ "ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ឱ្យបាននឹងន់ និងអភិវឌ្ឍន៍ពលកម្មឱ្យបានដុះដាលពេញទំហឹង" ។ ការប្រកាសជាសកលនូវសិទ្ធិមនុស្សចែងថា "ការសិក្សាអប់រំផ្នែកបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវតែបង្កើតឱ្យមានជាទូទៅ (មាត្រា ២៦ (១) ។ ស្របតាមការប្រកាសនោះ គណៈកម្មាធិការយល់ឃើញថា TVE បង្កើតជាអង្គធាតុទាំងមូលគ្រប់កំរិតការសិក្សា ។

១៦- ការនាំមកនូវបច្ចេកវិទ្យា និងការងារសកល មិនគួរស្ថិតតែក្នុងរង្វង់ដោយឡែកពីកម្មវិធី TVE ទេ ប៉ុន្តែគួរតែយល់ថាវាគឺជាសមាសភាគនៃការសិក្សាអប់រំទូទៅ ។ យោងតាមអនុសញ្ញា UNESCO ផ្នែកសិក្សាអប់រំបច្ចេកទេស និងវិជ្ជាជីវៈ (១៩៨៩) TVE មាន "គ្រប់ទំនាក់ទំនងនៃដំណើរការសិក្សាអប់រំទាំងអស់ដែលពាក់ព័ន្ធ បន្ថែមទៅលើចំណេះដឹងទូទៅ ការសិក្សាអំពីបច្ចេកវិទ្យា និងវិទ្យាស្សង់ដែលពាក់ព័ន្ធ ហើយនិងការចាប់ទទួលយកនូវការអនុវត្តន៍ជំនាញការយល់ដឹង អត្តចារិក និងការយល់ដឹងដែលទាក់ទងទៅនឹងមុខរបរក្នុងផ្នែកសេដ្ឋកិច្ច និងជីវិតសង្គមផ្សេងៗ ។ ទស្សនៈនេះ ក៏ឆ្លុះបញ្ចាំងខ្លះៗផងដែរនៅក្នុងអនុសញ្ញាអង្គការការងារអន្តរជាតិ ។ ការយល់ក្នុងផ្លូវនេះ សិទ្ធិទទួលនូវ TVE មានទិដ្ឋភាពដូចតទៅនេះ :

ក- អាចធ្វើឱ្យសិស្សទទួលនូវចំណេះដឹង និងជំនាញដែលចូលរួមដល់ការអភិវឌ្ឍន៍បុគ្គល ជំនឿលើខ្លួន និង ការអាចរកការងារធ្វើបាន ហើយនិងធ្វើឱ្យកាន់តែប្រសើនូវផលិតភាពនៃគ្រួសារ និងសហគមរបស់គេ រួមទាំងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច នៃរដ្ឋភាគីផង ។

ខ- រកផលពីមូលដ្ឋានសិក្សាអប់រំ វប្បធម៌ និងសង្គមកិច្ច នៃពលរដ្ឋដែលពាក់ព័ន្ធដូចជា ជំនាញ ចំណេះដឹង និងកំរិតនៃគុណភាព ដែលត្រូវការក្នុងផ្នែកផ្សេងៗនៃសេដ្ឋកិច្ច និង សុខភាពលើរូបរាងកាយ សុវត្ថភាព និងសុខមាលភាព ។

គ- ផ្តល់ការបណ្តុះបណ្តាលឡើងវិញដល់មនុស្សពេញវ័យ ដែលចំណេះដឹង និងជំនាញរបស់គេបានក្លាយជាផុតសម័យ ដោយហេតុនៃការផ្លាស់ប្តូរផ្នែកបច្ចេកទេស សេដ្ឋកិច្ច ការងារ សង្គម និងអ្វីៗដទៃទៀត ។

ឃ- មានកម្មវិធីផ្តល់ដល់សិស្ស ពិសេសសិស្សមកពីប្រទេសអភិវឌ្ឍន៍ឱ្យមានឱកាសទទួលនូវ TVE នៅក្នុងរដ្ឋដទៃទៀត ក្នុងទស្សនៈវិស័យ ដើម្បីផ្ទេរ និងសំរបតាមបច្ចេកវិទ្យានោះឱ្យបានត្រឹមត្រូវ ។

ង- នៅក្នុងខ្លឹមសារនៃកិច្ចព្រមព្រៀងស្តីពីការមិនរើសអើង និងបទបញ្ញត្តិស្មើៗគ្នា មានកម្មវិធីពង្រឹង TVE សំរាប់ស្ត្រី នារី យុវជនចេញពីសាលា យុវជនដែលគ្មានការងារធ្វើ កុមារា កុមារីនៃអនិកជនដែលជាកម្មករ ជនភៀសខ្លួន ហើយនិងក្រុមជនដែលចាញ់ប្រៀបគេ ។

## មាត្រា ១៣ (២) គ : សិទ្ធិទទួលការសិក្សាអប់រំផ្នែកឧត្តមសិក្សា

១៧- ឧត្តមសិក្សាមានអង្គធាតុដូចជា ការមានថ្នាក់អាចរៀនបាន ការអាចចូលរៀនបាន ការអាចទទួលយកបាន និងការសំរបតាមការសិក្សាបាន ដែលជាអង្គធាតុរួមចំពោះការសិក្សាគ្រប់បែបផែន និងគ្រប់កំរិត ។

១៨- នៅពេលដែលមាត្រា ១៣(២) គ បានតាក់តែងឡើង នៅក្នុងបន្ទាត់តែមួយដូចគ្នានឹងមាត្រា ១៣(២) ខ មានភាពខុសគ្នាបីយ៉ាងរវាងបទបញ្ញត្តិពីរ ។ មាត្រា ១៣(២) គ រួមគ្នា ការយោងទៅលើការសិក្សាអប់រំ "ក្នុងបែបបទខុសគ្នា" និងដោយឡែកពី TVE ។ មតិរបស់គណៈកម្មាធិការយល់ថា ការខ្វះខាតពីរនេះ ឆ្លុះបញ្ចាំងតែទៅលើការខុសគ្នានៃការសង្កត់ធ្ងន់រវាង មាត្រា ១៣(២) ខ និង គ ។ ប្រសិនបើឧត្តមសិក្សាត្រូវតែឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់និស្សិតក្នុងផ្នែកសង្គម និងវប្បធម៌ខុសៗគ្នា គឺត្រូវតែមានកម្មវិធីសិក្សាផ្លាស់ប្តូរ និងផ្តល់នូវប្រពន្ធ័ប្លែកៗ ដូចជាការរៀនពីចម្ងាយ ។ ដូច្នេះក្នុងការអនុវត្តន៍ជាក់ស្តែង ទាំងការសិក្សាផ្នែកមធ្យមសិក្សា និងឧត្តមសិក្សាត្រូវតែមានជាប្រចាំគ្រប់ទំរង់ទាំងអស់ ។ ដោយមានការភ្លេចចែងក្នុងមាត្រា ១៣(២) គ អំពីការយោងជាក់លាក់លើការសិក្សាផ្នែកបច្ចេកទេស និងវិជ្ជាជីវៈ បានធ្វើឱ្យមាត្រា ៦(២) នៃកិច្ចព្រមព្រៀង និងមាត្រា ២៦(១) របស់ UDHR, TVE បង្កើតបានជាសមាសភាគទាំងមូលគ្រប់កំរិតការសិក្សាអប់រំ រួមទាំងការសិក្សាផ្នែកឧត្តមសិក្សាផង ។

១៩- ភាពខុសគ្នាទីបី និងដ៏សំខាន់រវាងមាត្រា ១៣(២) ខ និង គ គឺនៅត្រង់ថា ពេលដែលការសិក្សាផ្នែកមធ្យមសិក្សា "ត្រូវតែធ្វើឱ្យមានជាប្រចាំ អាចចូលសិក្សាបានដល់ជនគ្រប់រូប ឯការសិក្សាផ្នែកឧត្តមសិក្សាត្រូវតែឱ្យមានសមភាពក្នុងការអាចចូលសិក្សាបានដល់ជនទូទៅ ដោយផ្អែកលើមូលដ្ឋានសមត្ថភាព" ។ ស្របតាមមាត្រា ១៣ (២) គ ថ្នាក់ឧត្តមសិក្សា "មិនអាចត្រូវតែមានជាប្រចាំទូទៅទេ" ប៉ុន្តែមានជាប្រចាំ "លើមូលដ្ឋានសមត្ថភាព" ។ សមត្ថភាពរបស់ឯកត្តបុគ្គល គួរតែត្រូវធ្វើការវាយតម្លៃ ដោយយោលទៅតាមរាល់ជំនាញ និងបទពិសោធន៍របស់និស្សិតទាំងអស់ ។

២០- កន្លងមកដោយពាក្យពេចន៍នៅក្នុងមាត្រា ១៣(២) ខ និង ខ ដូចគ្នា (ឧទាហរណ៍ "ការបញ្ចូលជាលំដាប់នូវការសិក្សាដោយឥតគិតថ្លៃ") សូមអានយោបល់ពីមុនក្នុងមាត្រា ១៣ (២) ខ ។

## មាត្រា ១៣ (២) ឃ : សិទ្ធិទទួលការសិក្សាគ្រឹះ

២១- ការសិក្សាអប់រំគ្រឹះមានអង្គធាតុដូចជា ការមានថ្នាក់ជាប្រចាំ ការអាចចូលសិក្សាបាន ការទទួលចូលរៀនបាន និងការយកលំនាំតាម ដែលជាអង្គធាតុរួមក្នុងការសិក្សាអប់រំរាល់បែបបទ និងគ្រប់កំរិតទាំងអស់ ។

២២- ចំពោះន័យទូទៅវិញ ការសិក្សាអប់រំគ្រឹះទាក់ទងនឹងការសិក្សាមូលដ្ឋាន ដូចចែងក្នុងសេចក្តីប្រកាសសកលផ្នែកសិក្សាអប់រំដល់ជនទាំងឡាយ ។ អនុលោមតាមមាត្រា ១៣(២) ឃ "ជនដែលមិនបានទទួល និងបញ្ចប់នូវរយៈកាលនៃការសិក្សាផ្នែកបឋមសិក្សាទេ" មានសិទ្ធិទទួលការសិក្សាអប់រំគ្រឹះ ឬការសិក្សាមូលដ្ឋាន ដូចមានចែងក្នុងសេចក្តីប្រកាសសកលផ្នែកអប់រំដល់ជនទាំងឡាយ ។

២៣- ចាប់ពីជនគ្រប់រូបមានសិទ្ធិតាមការពេញចិត្តរបស់ខ្លួនចំពោះ "មូលដ្ឋានរៀនសូត្រតាមត្រូវការ" ដូចការយល់ឃើញពីសេចក្តីប្រកាសសកល សិទ្ធិទទួលការសិក្សាគ្រឹះនេះមិនកំរិតតែចំពោះតែជន "ដែលមិនបានទទួល ឬ បញ្ចប់រយៈពេលពេញលេញ តែការសិក្សាអប់រំផ្នែកបឋមសិក្សាទេ" ។ សិទ្ធិទទួលការសិក្សាគ្រឹះផ្តល់ដល់ជនទាំងឡាយ ដែលមិនបានបញ្ចប់ "ការសិក្សាមូលដ្ឋាន ដែលខ្លួនត្រូវការ" ។

២៤- គួរតែត្រូវសង្កត់ការពេញចិត្តលើសិទ្ធិនៃការសិក្សាគ្រឹះ ដែលមិនបានកំណត់ពីអាយុ ឬ ភេទឡើយ ។ ការសិក្សានេះផ្តល់ដល់កុមារា កុមារី យុវជន និងជនពេញវ័យ និងជនវ័យចាស់ផងដែរ ។ ដូច្នេះ ការសិក្សាគ្រឹះ គឺជាសមាសភាគទាំងមូលនៃការសិក្សាគ្រឹះ ជាសិទ្ធិចំពោះក្រុមជនគ្រប់អាយុកាល កម្មវិធីសិក្សា និងការផ្តល់ប្រព័ន្ធ ត្រូវតែប្រឹងឡើង ដែលសិស្សនិស្សិតគ្រប់វ័យ អាចចូលរៀនបានទាំងអស់ ។

## មាត្រា ១៣(២) ង : ប្រព័ន្ធសាលា, ប្រព័ន្ធសិក្សាបន្ថែម, លក្ខខណ្ឌឧបករណ៍សំរាប់បុគ្គលិកសិក្សា

២៥- ការតម្រូវអំពី "ការអភិវឌ្ឍន៍នូវប្រព័ន្ធសាលាគ្រប់កំរិត ត្រូវតែបន្តធ្វើឱ្យបានសកម្ម "មានន័យថា រដ្ឋភាគី ត្រូវមានកាតព្វកិច្ចយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងស្រុង សំរាប់ប្រព័ន្ធសាលារបស់ខ្លួន ។ យុទ្ធសាស្ត្រត្រូវមានការសិក្សាគ្រប់ជាន់ថ្នាក់ ប៉ុន្តែកិច្ចព្រមព្រៀងតម្រូវឱ្យរដ្ឋភាគីផ្តល់អាទិភាពដល់ការសិក្សាផ្នែកបឋមសិក្សា (សូមអានវាក្យខ័ណ្ឌ ៥១) ។

"ការបន្តធ្វើដំសកម្ម" គឺណែនាំឱ្យមានគ្រប់យុទ្ធសាស្ត្រ គួរតែទាក់ទាញក៏រិតនៃការគ្រប់គ្រងអំពីអាទិភាព ហើយក្នុងរាល់ព្រឹត្តិការណ៍ ត្រូវតែអនុវត្តន៍អោយបានហ្មត់ចត់ ។

២៦- ការតម្រូវអំពី "ប្រព័ន្ធសិក្សាបន្ថែមត្រូវតែបង្កើតឡើង" គួរតែមានក្នុងកិច្ចព្រមព្រៀងមិនរើសអើង និងបទបញ្ញត្តិសមភាព ។ ប្រព័ន្ធសិក្សាបន្ថែម គួរតែកែលំអសមភាព តែការអាចចូលសិក្សាបានសំរាប់ឯកត្តជនទាំងឡាយពីក្រុមជនដែលក្រីក្រ ។

២៧- ពេលដែលកិច្ចព្រមព្រៀងតម្រូវថា "លក្ខខ័ណ្ឌឧបករណ៍នៃបុគ្គលិកសិក្សាត្រូវតែកែលំអរជាបន្តបន្ទាប់" នៅក្នុងការអនុវត្តលក្ខខ័ន្ឌការងារទូទៅរបស់គ្រូបានចុះថយ ហើយខិតទៅរកក៏រិតទាបដែលមិនអាចទទួលយកបាននៅក្នុងរដ្ឋភាគីជាច្រើនប៉ុន្មានឆ្នាំថ្មីៗនេះ ។ មិនត្រឹមតែខ្វះនិរន្តភាពជាមួយនឹងមាត្រា ១៣(២) ង ទេ តែវាជាឧបសគ្គដ៏ធំចំពោះការធ្វើឱ្យបានសំរេចដ៏ពេញទំហឹងដល់សិទ្ធិទទួលការសិក្សាទៀតផង ។ គណៈកម្មាធិការបានកត់សំគាល់ដែរថា ទំនាក់ទំនងរវាងមាត្រា ១៣(២) ង, ២(២), ៣ និង ៦-៨ នៃកិច្ចព្រមព្រៀង, រួមមានសិទ្ធិរបស់គ្រូក្នុងការរៀបចំ និង តវ៉ារួមទាញការយកចិត្តទុកដាក់ពីរដ្ឋភាគី ដើម្បីភ្ជាប់នឹងអនុសាសន៏របស់ UNESCO/ILO ទាក់ទងនឹងលក្ខន្តិកៈរបស់គ្រូ (១៩៦៦) និងអនុសាសន៏របស់ UNESCO ទាក់ទងនឹងលក្ខន្តិកៗរបស់បុគ្គលិកសិក្សានៃថ្នាក់ឧត្តមសិក្សា (១៩៩៧) ហើយតម្រូវឱ្យរដ្ឋភាគីធ្វើរបាយការណ៍អំពីវិធានការណ៍ ដែលគេបានធ្វើ ដើម្បីធានាដល់បុគ្គលិកសិក្សានូវភាពរីករាយនឹងលក្ខខ័ណ្ឌ និងលក្ខន្តិកៈ ដែលសមគ្នានឹងនាទីរបស់គេ ។

## មាត្រា ១៣ (៣) និង (៤) : សិទ្ធិទទួលសេរីភាពក្នុងការអប់រំ

២៨- មាត្រា ១៣(៣) មានអង្គធាតុពីរ ដែលអង្គធាតុមួយនោះនិយាយថា រដ្ឋភាគីត្រូវគោរពសេរីភាពមាតាបិតា និងអាណាព្យាបាល ដើម្បីធានាថា ការអប់រំផ្នែកសាសនា និងសីលធមិនៃកូនរបស់គេស្របនឹងជំនឿរបស់គេ ។ គណៈកម្មាធិការមានទស្សនៈថា អង្គធាតុនៃមាត្រា ១៣(១៣) អនុញ្ញាតឱ្យមានប្រធានបទអំពីវិន័យសាធារណៈរបស់សាលា ដូចជាប្រវត្តិវិទ្យា សីលធមិទូទៅនៃសាសនា ប្រសិនបើបានផ្តល់ដោយមិនចំក៏ដោយ និងមានផ្លូវជាគោលដៅ គោរពនូវសេរីភាពនៃការបញ្ចេញមតិ សម្បជ្ជញ្ញៈ និងការចេញវាចា ។ គេកត់សំគាល់ថា ការអប់រំសាធារណៈរួមមានការណែនាំអំពីសាសនាដោយឡែកណាមួយ ឬ ជំនឿដែលមិនមាននិរន្តភាពជាមួយនឹងមាត្រា ១៣(៣) លើកលែងតែប្រការនេះធ្វើឡើងសំរាប់លើកលែងការមិនឱ្យរើសអើង ឬ លទ្ធភាពណាផ្សេងដែលតម្រូវចិត្តការប្រាថ្នារបស់មាតាបិតា និងអាណាព្យាបាល ។

២៩- អង្គធាតុទី២ នៃមាត្រា ១៣(៣) គឺ សេរីភាពរបស់មាតាបិតា និងអាណាព្យាបាល ដើម្បីជ្រើសរើសសាលាសាធារណៈណាមួយសំរាប់កូនរបស់ខ្លួន ដូចជាសាលាដែលស្របទៅនឹងស្តង់ដារអប្បរិមានៃការសិក្សាអប់រំ ដែលអាចដាក់ចុះ ឬ អនុម័តដោយរដ្ឋរបស់គេ ។ ករណីនេះ គួរអាននូវបទបញ្ញត្តិបន្ថែមនៃមាត្រា ១៣(៤) ដែលបញ្ជាក់ពីសេរីភាពរបស់

ឯកត្តបុគ្គល និងអង្គភាពដែលបង្កើត និងចាត់ចែងនូវស្ថាប័នអប់រំ ឧទាហរណ៍ ស្ថាប័នដែលស្របនឹងកម្មវត្ថុសិក្សា ដែលមានចែងក្នុងមាត្រា ១៣(១) និងមានស្តង់ដារអប្បរិមា ។ ស្តង់ដារអប្បរិមានេះ អាចទាក់ទងទៅនឹងបញ្ហាខ្លះ ដូចជាការចុះឈ្មោះចូលរៀន កម្មវិធីសិក្សា និងការទទួលស្គាល់នូវវិញ្ញាបនប័ត្រ ។ ស្តង់ដារនេះ ត្រូវតែនិរន្តភាពជាមួយនឹងកម្មវត្ថុសិក្សាដែលចែងក្នុងមាត្រា ១៣(១) ។

៣០- ក្រោមមាត្រា ១៣(៤) ម្នាក់ៗរួមទាំងជនបរទេសផង ត្រូវមានសេរីភាពក្នុងការកសាង និងចាត់ចែងស្ថាបន័អប់រំ ។ សេរីភាពនេះ ត្រូវលាតសន្ធឹងដល់អង្គភាពនានា ដូចជា នីតិបុគ្គល ។ សេរីភាពនេះមានជាអាទិ សិទ្ធបង្កើត និងចាត់ចែងរាល់ប្រភេទស្ថាប័នអប់រំ រួមមាន កន្លែងមើលក្មេង សកលវិទ្យាល័យ និងស្ថាប័នសំរាប់ការសិក្សាវ័យចាស់ ។ ដោយមានគោលការណ៍ ស្តីពីការមិនរើសអើង ឱកាសសមភាព និងការចូលរួមដ៏មានប្រសិទ្ធភាពក្នុងសង្គមសំរាប់មនុស្សទូទៅទាំងអស់ រដ្ឋមានកាតព្វកិច្ចដើម្បីធានាថា សេរីភាពដែលមានចែងក្នុងមាត្រា ១៣(៤) មិនបាននាំទៅរកភាពអយុត្តិធមិហួសហេតុនៃឱកាសសិក្សារៀនសូត្រ ចំពោះក្រុមខ្លះនៅក្នុងសង្គម ។

## មាត្រា ១៣ : ប្រធានបទពិសេសនៃការអនុវត្តលក្ខណៈទូលាយ ការមិនរើសអើង និងការទទួលភាពស្មើភាព

៣១- ការហាមឃាត់ប្រឆាំងការរើសអើងបានចែងនៅក្នុងមាត្រា ២(២) នៃកិច្ចព្រមព្រៀងត្រូវស្ថិតនៅក្នុងកម្មវត្ថុ ដែលគ្មានការសម្រេចជាលំដាប់ ឬ អាចគ្មានប្រភពធនធានអ្វី ។ ការហាមឃាត់នេះ អនុវត្តទាំងស្រុង និងដោយភ្លាមៗចំពោះរាល់ទិដ្ឋភាពនៃការសិក្សាអប់រំ និងក្តោបរាល់មូលដ្ឋាននៃការរើសអើងជាអន្តរជាតិទាំងអស់ ។ គណៈកម្មាធិការបកស្រាយ មាត្រា ២(២) និង ៣ ដើម្បីជាការបំភ្លឺដល់អនុសញ្ញា UNESCO ប្រឆាំងនឹងការរើសអើងក្នុងការសិក្សាបទបញ្ញត្តិពាក់ព័ន្ធនឹងអនុសញ្ញា ស្តីពីការលុបបំបាត់រាល់សណ្ឋាននៃការរើសអើងប្រឆាំងនឹងទ្រីស្តី, អនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងពូជសាសាន៍, អនុសញ្ញាស្តីពីសិទ្ធិកុមារ, និងអនុសញ្ញាប្រឆាំងនឹងជនជាតិភាគតិច និងពួកកុលសម្ព័ន្ធ (អនុសញ្ញា ILO ១៦៩), ហើយនិងមានប្រាថ្នាទាញការចាប់អារម្មណ៍ដោយឡែកចំពោះបញ្ហាដែលមានតទៅនេះ ។

៣២- ការរើសយកនូវមធ្យោបាយពិសេសបណ្តោះអាសន្ន ក្នុងបំណងនាំមកនូវអង្គហេតុសមភាពចំពោះបុរស និងស្ត្រី , និងក្រុមជនដែលក្រីក្រជាងគេ គឺមិនមែនជាការរំលោភសិទ្ធិដែលមិនរើសអើងលើការសិក្សាអប់រំទេ រហូតដល់ថ្ងៃដែលវិធានការណ៍មិននាំទៅដល់ការថែទាំនូវស្តង់ដារដែលគ្មានភាពស្មើគ្នា ឬ បែកឃ្លាតពីគ្នាលើក្រុមខុសគ្នាទាំងនោះ ហើយឧទាហរណ៍ថា ក្រុមទាំងនោះពុំបានធ្វើបន្តក្រោយពីកម្មវត្ថុដែលគេអនុវត្តនោះពុំបានធ្វើឱ្យសំរេចបាន ។

៣៣- ក្នុងកាលៈទេសៈខ្លះ ប្រព័ន្ធសិក្សាបែកគ្នានេះ ឬ ក៏ស្ថាប័ននៃក្រុមដែលមានចែងជាប្រភេទៗ ក្នុងមាត្រា ២(២) ត្រូវតែចាត់ថា ពុំបានបង្កការរំលោភលើកិច្ចព្រមព្រៀងទេ ។ ក្នុងករណីនេះ គណៈកម្មាធិការបញ្ជាក់ថា មាត្រា ២ នៃអនុសញ្ញា UNESCO ប្រឆាំងនឹងការរើសអើងក្នុងការសិក្សា (១៩៦០) ។

៣៤- គណៈកម្មាធិការកត់សំគាល់មាត្រា ២ នៃអនុសញ្ញា ស្តីពីសិទ្ធិកុមារ និងមាត្រា ៣(ង) នៃអនុសញ្ញា UNESCO ប្រឆាំងនឹងការរើសអើងក្នុងការសិក្សាអប់រំ និងបានបញ្ជាក់ថាគោលការណ៍នៃការមិនរើសអើងអនុវត្តលើរាល់ជនទាំងអស់ដែលមានអាយុត្រូវចូលសាលា រស់នៅលើទឹកដីនៃរដ្ឋភាគី រួមមានជនបរទេស និងដោយមិនគិតដល់ជនដែលមានសិទ្ធិស្របច្បាប់របស់ខ្លួន ។

៣៥- ភាពខុសគ្នាដ៏ខ្លាំងក្នុងការចំណាយចេញ គោលនយោបាយដែលនាំឱ្យមានលទ្ធផលជាគុណភាពអប់រំខុសគ្នា សំរាប់មនុស្សរស់នៅតាមទីតាំងភូមិសាស្ត្រខុសគ្នាអាចបង្កើតជាការរើសអើងក្រោមកិច្ចព្រមព្រៀង ៣៦ ។ គណៈកម្មាធិការបញ្ជាក់តាមរយៈវាក្យខ័ណ្ឌ ៣៥ នៃយោបល់ទូទៅលេខ ៥ ដែលបានថ្លែងពីបទបញ្ហាមនុស្សដែលមានពិការភាព នៅក្នុងខ្លឹមសារនៃសិទ្ធិទទួលការសិក្សាអប់រំ និងវាក្យខ័ណ្ឌ ៣៦-៤២ នៃយោបល់ទូទៅលេខ ៦ ដែលថ្លែងពីបញ្ហាមនុស្សវ័យចាស់ដែលទាក់ទងនឹងមាត្រា ១៣-១៥ ។

៣៦- គណៈកម្មាធិការអះអាងពីវាក្យខ័ណ្ឌ ៣៥ នៃយោបល់ទូទៅលេខ ៥ ដែលសម្តែងពីបញ្ហាមនុស្សពិការភាព នៅក្នុងខ្លឹមសារនៃសិទ្ធិទទួលការសិក្សាអប់រំ និងវាក្យខ័ណ្ឌ ៣៦-៤២ នៃយោបល់ទូទៅលេខ ៦ ដែលសំដែងអំពីបញ្ហាមនុស្សវ័យចាស់ដែលទាក់ទងទងទៅនឹងមាត្រា ១៣-១៥ នៃកិច្ចព្រមព្រៀង ។

៣៧- រដ្ឋភាគី ត្រូវតែត្រួតពិនិត្យការសិក្សាអប់រំឱ្យបានជិតស្និទ្ធ រួមមានរាល់គោលនយោបាយដែលពាក់ព័ន្ធទាំងឡាយ, ស្ថាប័ន, កម្មវិធី, ការចំណាយលើរូបភាពនានា ហើយនិងការប្រតិបត្តិដទៃទៀត ដើម្បីនឹងធ្វើអត្តសញ្ញាណ និងចាត់វិធានការណ៍ដើម្បីលើកឡើងវិញនូវអ្វីដែលជាការរើសអើងពិតប្រាកដនោះ ។ ទិន្នន័យផ្នែកអប់រំ គួរតែបំបែកចំនួននៃមូលដ្ឋានដែលហាមឃាត់ការរើសអើង ។

<u>ការសិក្សាអំពីសេរីភាព និងស្វ័យភាពនៃស្ថាប័ន</u>

៣៨- ជាពន្លឺក្នុងការពិនិត្យរបស់គណៈកម្មាធិការលើរបាយការណ៍របស់រដ្ឋភាគីជាច្រើន បានឱ្យគេបង្កើតជាទស្សនៈថា សិទ្ធិទទួលការអប់រំអាចនឹងនាំឱ្យពេញចិត្តបាន ប្រសិនបើវារួមផ្សំដោយការសិក្សាអំពីសេរីភាពពីបុគ្គលិក និង និស្សិតដែរ ។ អនុលោមតាមនោះ ទោះជាយ៉ាងណាក្តីបញ្ហានេះមិនបាននិយាយច្បាស់លាស់ក្នុងមាត្រា ១៣ ទេ ។ ជាការសមស្រប និងចាំបាច់សំរាប់គណៈកម្មាធិការ ដើម្បីធ្វើការពិនិត្យអំពីការសិក្សាអំពីសេរីភាព ។ ការសំគាល់ដូចតទៅនេះ បានធ្វើឱ្យស្ថាប័ន

ឧត្តមសិក្សានានាយកចិត្តទុកដាក់ដោយឡែក ព្រោះថាតាមបទពិសោធន៍របស់គណៈកម្មាធិការ បុគ្គលិក និង និស្សិតនៃឧត្តមសិក្សាបានទទួលរងជាពិសេសនូវបញ្ហាដែលទាក់ទងនឹងនយោបាយ និងសម្ពាធផ្សេងៗទៀតដែលធ្វើឱ្យអន្តរាយដល់ការសិក្សាអំពីសេរីភាព ។ គណៈកម្មាធិការមានប្រាថ្នាសង្កត់ធ្ងន់ថា បុគ្គលិក និងនិស្សិតផ្នែកអប់រំទូទៅទាំងអស់មានសិទ្ធិទទួលនូវការសិក្សាអំពីសេរីភាព ហើយក្នុងបណ្តាការសង្កេតនោះមានការអនុវត្តទូទៅ ។

៣៩- សមាជិកទាំងឡាយនៃការសិក្សាអំពីសហគម ទោះឯកត្តបុគ្គល ឬ រួមក្តី មានសេរីភាពដើម្បីតាមដាន អភិវឌ្ឍន៍ និងផ្ទេរចំណេះដឹង និងគំនិតតាមរយៈការស្រាវជ្រាវ, ការបង្រៀន, ការសិក្សា, ការពិភាក្សា, ការចងក្រងឯកសារ, ការផលិត, ការបង្កើត ឬ ការសរសេរ ។ ការសិក្សាអំពីសេរីភាពរួមមាន សេរីភាពមនុស្សក្នុងការបញ្ចេញមតិដោយសេរីអំពីស្ថាប័ន ឬ ប្រព័ន្ធ ដែលគេធ្វើការទីនោះ ដើម្បីបំពេញការងាររបស់គេដោយគ្មានការរើសអើង ឬ ភ័យខ្លាច ពីការកៀបសង្កត់ពីរដ្ឋ ឬ ជនណាមួយដទៃទៀត ដើម្បីចូលរួមចំណែកក្នុងវិជ្ជាជីវៈ ឬ ជាតំណាងអង្គភាពសិក្សានានា ហើយនិងរីករាយអំពីការទទួលស្គាល់ជាអន្តរជាតិអំពីសិទ្ធិមនុស្ស ដែលអាចនឹងអនុវត្តដល់ជនដទៃទៀត នៅក្នុងយុត្តាធិការតែមួយ ។ ការរីករាយទទួលនូវការសិក្សាអំពីសេរីភាពនាំមកនូវកាតព្វកិច្ចរបស់វា ដូចជា ភារកិច្ចគោរពនូវការសិក្សា អំពីសេរីភាពរបស់អ្នកដទៃ ដើម្បីធានាពីការពិភាក្សាដ៏សមរម្យអំពីទស្សនៈផ្សេងគ្នា និងដើម្បីថែទាំជនទូទៅកុំឱ្យមានការរើសអើងទៅលើមូលដ្ឋានដែលហាមឃាត់ណាមួយក្តី ។

៤០- ការពេញចិត្តចំពោះការសិក្សាអំពីសេរីភាព តម្រូវនូវភាពស្វយ័តនៃស្ថាប័នឧត្តមសិក្សា ។ ស្វ័យភាពមានន័យថា កំរិតនៃការគ្រប់គ្រងដោយខ្លួនឯង ចាំបាច់សំរាប់ឱ្យមានប្រសិទ្ធភាពនៃការធ្វើសេចក្តីសំរេចការងារ ដោយស្ថាប័នឧត្តមសិក្សាចំពោះអ្វីដែលជាកិច្ចការសិក្សារបស់គេ, ស្តង់ដារ, ការគ្រប់គ្រង និងសកម្មភាពពាក់ព័ន្ធដទៃទៀត ។ ប៉ុន្តែការគ្រប់គ្រងដោយខ្លួនឯង ត្រូវតែមាននិរន្តភាពនឹងប្រព័ន្ធនៃការទទួលខុសត្រូវសាធារណៈ ជាពិសេសក្នុងការគោរពថវិកា ដែលបានផ្តល់ឱ្យដោយរដ្ឋ ។ និយាយអំពីការវិនិយោគសាធារណៈដ៏ប្រសើរសំខាន់នោះ ដែលបានធ្វើឡើងក្នុងវិស័យឧត្តមសិក្សាតុល្យភាពដ៏សមស្របស្របត្រូវតែធ្វើឡើងរវាងភាពស្វយ័ត និងការទទួលខុសត្រូវនៃស្ថាប័ន ។ ពេលដែលគ្មានគំរូណាមួយនោះ ការសំរបសំរួលផ្នែកស្ថាប័នគួរតែឱ្យបានត្រឹមត្រូវ យុត្តិធម៌ និងសមភាព ហើយក៏ត្រូវមានតម្លាភាព និងការចូលរួមផងដែរ ។

<u>វិន័យក្នុងសាលា</u>

៤១- តាមទស្សនៈរបស់គណៈកម្មាធិការ ការផ្តន្ទាទោសលើរូបរាងកាយមិនមាននិរន្តភាពទៅនឹងគោលការណ៍ណែនាំសំខាន់នៃច្បាប់សិទ្ធិមនុស្សអន្តរជាតិទេដែលបានចែងនៅក្នុងបុព្វកថារបស់សេចក្តីប្រកាសសកលពីសិទ្ធិមនុស្ស ហើយនិងកិច្ចព្រម-ព្រៀងទាំងពីរ : ភាពថ្លៃថ្នូរនៃបុគ្គល ។ ទិដ្ឋភាពផ្សេងទៀតនៃវិន័យសាលាក៏អាចមិននិរន្តភាពផងដែរនឹងភាពថ្លៃថ្នូរនៃមនុស្ស ដូចជាការអាម៉ាស់មុខសាធារណៈ ។ តើគួរទេថា គ្រប់ពេលនៃវិន័យរំលោភសិទ្ធិដទៃទៀតក្រោមកិច្ចព្រមព្រៀង

នេះ ដូចជាសិទ្ធិទទួលម្ហូបអាហារ ។ រដ្ឋភាគីត្រូវបានតម្រូវឱ្យចាត់វិធានការណ៍ដើម្បីធានាថា វិន័យ ដែលមិនមាននិរន្តភាពជាមួយនឹងកិច្ចព្រមព្រៀងនឹងមិនកើតឡើងនៅក្នុងស្ថាប័នអប់រំសាធារណៈ ឬ ឯកជនណាមួយ នៅក្នុងវង្វង់យុត្តាធិការរបស់ស្ថាប័ននោះ ។ គណៈកម្មាធិការស្វាគមន៍គំនិតដែលលើកឡើងដោយរដ្ឋភាគី ដែលលើកទឹកចិត្តដ៏សកម្មដល់សាលាដើម្បីបញ្ចូលជាវិជ្ជមាន "អំពីការដោះស្រាយបញ្ហាដោយគ្មានហឹង្សា ចំពោះវិន័យសាលា" ។

<u>ព្រំដែននៃមាត្រា ១៣</u>

៤២- គណៈកម្មាធិការប្រាថ្នាសង្កត់ធ្ងន់ថា ការកំណត់ព្រំដែននៃខមួយដែលចែងក្នុងកិច្ចព្រមព្រៀង មាត្រា ៤ មានបំណងសំខាន់ដើម្បីការពារសិទ្ធិបុគ្គលជាជាងបណ្តោយឱ្យមានការតម្រូវឱ្យមានការកំណត់ដោយរដ្ឋ ។ ហេតុដូច្នេះហើយ រដ្ឋភាគីដែលបិទសកលវិទ្យាល័យ ឬ ស្ថាប័នអប់រំដទៃទៀត ដោយផ្អែកលើមូលដ្ឋាន ដូចជា សន្តិសុខជាតិ ឬ ការរក្សានូវរបៀបរៀបរយសាធារណៈ ដែលមានបន្ទុកធ្វើក្នុងការបញ្ជាក់នូវមធ្យោបាយធ្ងន់ធ្ងរ ក្នុងទំនាក់ទំនងទៅនឹងអង្គធាតុនិមួយៗដែលបានធ្វើអត្តសញ្ញាណក្នុងមាត្រា ៤ ។

## II . ភាតព្វកិច្ច និងការរំលោភរបស់រដ្ឋភាគី

## ភាតព្វកិច្ចស្របច្បាប់ទូទៅ

៤៣- កាលបើកិច្ចព្រមព្រៀងផ្តល់នូវការសំរេចផលជាលំដាប់ និងជូនដំណឹងពីភាពស្មុគស្មាញ ដោយហេតុមានការកំណត់ភាពមានមូលធនត្រៀម ក៏មានការតម្រូវដល់រដ្ឋភាគីនូវកាតព្វកិច្ចផ្សេងៗជាច្រើន ដែលត្រូវតែធ្វើឱ្យបានផលភ្លាមៗ ។ រដ្ឋភាគីមានកាតព្វកិច្ចភ្លាមៗទៅនឹងសិទ្ធិទទួលការសិក្សាអប់រំ ដូចជា "កាធានា" ថា សិទ្ធិ "នឹងត្រូវបានអនុវត្តដោយគ្មានការរើសអើងគ្រប់បែបយ៉ាង" (មាត្រា ២ [២] ហើយនិងកាតព្វកិច្ច ដើម្បីឱ្យ "បោះជំហានទៅមុខ" (មាត្រា ២ [១] ឆ្ពោះទៅរកការសំរេចទាំងស្រុងនូវមាត្រា ១៣ ។ ជំហាននេះត្រូវតែ "គិតទុកជាមុន, មានរូបរាង និងមានទិសដៅ" ឆ្ពោះទៅរកការសំរេចបានទាំងស្រុងនូវសិទ្ធិទទួលការសិក្សាអប់រំ ។

៤៤- ការសំរេចបាននូវសិទ្ធិទទួលការសិក្សាអប់រំទាន់ពេល មានន័យថា "ដោយលំដាប់ថ្នាក់" មិនគួរត្រូវបកស្រាយជាការដកហូតនូវកាតព្វកិច្ចរបស់រដ្ឋភាគីនៃមាតិកាសំខាន់ទាំងអស់ទេ ។ ការសំរេចដ៏ប្រសើរនេះ មានន័យថា រដ្ឋភាគីមានកាតព្វកិច្ចដោយឡែក និងបន្តបន្ទាប់ "ដើម្បីបោះជំហានឱ្យបានលើន និងដ៏មានប្រសិទ្ធភាពទៅតាមលទ្ធភាពដែលធ្វើបាន" ឆ្ពោះទៅរកផលសំរេចទាំងស្រុងនូវមាត្រា ១៣ ។

៤៥- នេះគឺជាការសន្មត់ដ៏ខ្លាំងក្លា ប្រឆាំងនឹងការអនុញ្ញាតឱ្យមានការប្រើនូវមធ្យោបាយត្រឡប់ក្រោយ លើសិទ្ធិទទួលការសិក្សាអប់រំ ក៏ដូចជាសិទ្ធិដទៃទៀត ដូចបានរៀបរាប់ក្នុងកិច្ចព្រមព្រៀង ។ ប្រសិនបើមានប្រើមធ្យោបាយដើរថយក្រោយ

ដែលគិតទុកជាមុនដូច្នេះ រដ្ឋភាគីមានបន្ទុកបង្ហាញថា រដ្ឋទាំងនោះត្រូវបានគេបញ្ចូលនូវកាតព្វកិច្ច ក្រោយពីមានការពិចារណាដ៏ហ្មត់ចត់ស្តីអំពីច្រកដទៃទៀត ហើយដែលរដ្ឋនោះត្រូវបញ្ជាក់ទាំងស្រុងដោយឯកសារយោងទៅនឹងសិទ្ធិទាំងមូលដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង និងនៅក្នុងខ្លឹមសារនៃការប្រើទាំងស្រុងនូវធនធាន ដែលបានត្រៀមជាអតិបរិមារបស់រដ្ឋភាគី ។

៤៦- សិទ្ធិទទួលការសិក្សាអប់រំ ក៏ដូចជាសិទ្ធិមនុស្សទាំងអស់ដែរ បានដាក់ចុះនូវបីប្រភេទ និងកំរិតកាតព្វកិច្ច លើរដ្ឋភាគី : កាតព្វកិច្ចគោរព ការពារ និងបំពេញ ។ ត្រឡប់មកវិញ កាតព្វកិច្ចបំពេញបានចុះបញ្ជីទាំងពីរ គឺ កាតព្វកិច្ចសំរបសំរួល និងកាតព្វកិច្ចផ្តល់ឱ្យ ។

៤៧- កាតព្វកិច្ចគោរព តម្រូវឱ្យរដ្ឋភាគីចៀសវាងនូវមធ្យោបាយដែលរារាំង ឬ ហាមឃាត់ការប្រើប្រាស់នូវសិទ្ធិទទួលការសិក្សាអប់រំ ។ កាតព្វកិច្ចការពារតម្រូវឱ្យរដ្ឋភាគីចាត់វិធានការហាមឃាត់ភាគីទីបី កុំឱ្យមករំខានទៅនឹងការប្រើសិទ្ធិទទួលការសិក្សាអប់រំ ។ កាតព្វកិច្ចបំពេញ (សំរួល) តម្រូវឱ្យរដ្ឋភាគីចាត់វិធានការណ៍វិជ្ជមាន ដើម្បីអាចធ្វើឱ្យមានលទ្ធភាព និងឧត្តម្ភដល់ជន និងសហគមន៍ទាំងឡាយ ប្រើនូវសិទ្ធទទួលការសិក្សាអប់រំ ។ ទីបញ្ចប់ រដ្ឋភាគីមានកាតព្វកិច្ច ដើម្បីបំពេញ (ផ្តល់ជូន) សិទ្ធពិសេសដែលមានចែងក្នុងកិច្ចព្រមព្រៀង នៅពេលដែលបុគ្គល ឬ ក្រុមណាមិនមានលទ្ធភាព ដើម្បីសំរេចបាននូវសិទ្ធិរបស់ខ្លួន ដោយហេតុផលមិនអាចត្រួតត្រាបានដោយខ្លួនគេ ដោយមធ្យោបាយតាមការចាត់ចែងរបស់គេ ។ ទោះយ៉ាងណាក្តី ការតម្រូវឱ្យមានកាតព្វកិច្ចនេះ ជានិច្ចជាកាលត្រូវស្ថិតក្រោមអត្ថបទនៃកិច្ចព្រមព្រៀង ។

៤៨- ក្នុងគោលគំនិតនេះ ទ្រង់ទ្រាយពីរនៃមាត្រា ១៣ តម្រូវអោយមានទម្ងន់សង្កត់ ។ ទី ១ វាមានភាពច្បាប់លាស់ថា មាត្រា ១៣ បាននិយាយអំពី**រដ្ឋ** ដែលត្រូវមានការទទួលខុសត្រូវសំខាន់ក្នុងការផ្តល់ដោយផ្ទាល់នូវការសិក្សាអប់រំគ្រប់កាលៈទេសៈទាំងអស់ ។ **រដ្ឋភាគី** ឧទាហរណ៍ ទទួលស្គាល់ថា "ការអភិវឌ្ឍន៍នូវប្រព័ន្ធសាលានៅគ្រប់កំរិតត្រូវតែធ្វើការតាមដានឱ្យបានសកម្ម" (មាត្រា ១៣(២) ង ។ ទី ២ បើយើងឱ្យនិយមន័យខុសគ្នានៃមាត្រា ១៣(២) នៅក្នុងការអប់រំផ្នែកបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងការសិក្សាគ្រឹះ ទំហំការងារ នៃកាតព្វកិច្ចរបស់រដ្ឋភាគី ដើម្បីបំពេញ (ផ្តល់ជូន) គឺ មិនដូចគ្នាទៅនឹងកំរិតសិក្សាអប់រំទាំងអស់ទេ ។ ហេតុនេះ ក្នុងការបំភ្លឺនូវខ្លឹមសារនៃកិច្ចព្រមព្រៀង រដ្ឋភាគីមានកាតព្វកិច្ចប្រសើរ ដើម្បីបំពេញ (ផ្តល់ជូន) នូវសិទ្ធិទទួលការសិក្សាអប់រំ ប៉ុន្តែទំហំនៃកាតព្វកិច្ចនេះ មិនមែនឯកភាពគ្នាទៅនឹងកំរិតសិក្សាទាំងអស់ទេ ។ គណៈកម្មាធិការពិនិត្យឃើញថា ការបកស្រាយនូវកាតព្វកិច្ចនេះ គឺ ដើម្បីបំពេញ (ផ្តល់ជូន) ទៅនឹងមាត្រា ១៣ ដែលប៉ះទង្គិចគ្នាជាមួយនឹងច្បាប់ និងការអនុវត្តន៍របស់ប្រទេសភាគីជាច្រើន ។

កាតព្វកិច្ចស្របច្បាប់ពិសេស

៤៩- រដ្ឋភាគីត្រូវបានគេតម្រូវឱ្យធានាថា កម្មវិធីសិក្សាសំរាប់គ្រប់កំរិតនៃប្រព័ន្ធសិក្សាអប់រំ បានចាត់ចែងទៅតាមកម្មវត្ថុដូចបានធ្វើអត្តសញ្ញាណក្នុងមាត្រា ១៣(១) ។ រដ្ឋទាំងនោះត្រូវមានកាតព្វកិច្ចកសាង និងថែទាំតម្លាភាព និងប្រព័ន្ធដែលមានប្រសិទ្ធភាព ដែលត្រួតពិនិត្យថា តើមាន ឬ គ្មានការសិក្សាអប់រំ តាមពិតបានចាត់ចែងទៅនឹងកម្មវត្ថុសិក្សាដូចមានចែងក្នុងមាត្រា ១៣(១) ។

៥០- ចំពោះមាត្រា ១៣ (២) វិញ រដ្ឋមានកាតព្វកិច្ចគោរព ការពារ និងបំពេញនូវទ្រង់ទ្រាយសំខាន់ៗ" (ការត្រៀមឱ្យមាន, ការអាចចូលរៀនបាន, ការទទួលយកបាន ការអនុវត្តន៏បាន) នូវសិទ្ធិទទួលការសិក្សាអប់រំ ។ តាមមធ្យោបាយប្រើរូបភាព រដ្ឋត្រូវគោរពឱ្យមានការសិក្សាអប់រំដោយមិនបិទសាលាឯកជន, ការពារនូវភាពអាចឱ្យចូលសិក្សាបាន ដោយធានាដល់ភាគីទី ៣ រួមមានមាតាបិតា និង និយោជក, មិនបញ្ឈប់នារីមិនឱ្យទៅរៀន, **បំពេញ**(សំរួល) ការអាចទទួលឱ្យចូលរៀនបានដោយចាត់វិធានការវិជ្ជមានដល់ជនជាតិភាគតិច និងជនអន្តោប្រវេសន៍, ហើយអោយការសិក្សានេះមានគុណភាពល្អសំរាប់ជនទូទៅ, **បំពេញ** (ផ្តល់ជូន) ការសំរួលខ្លួនតាមការសិក្សាដោយរៀបរៀង និងផ្តល់ធនធានល្អដល់កម្មវិធីសិក្សាដែលឆ្លុះបញ្ចាំងនូវការចាំបាច់ទាន់សម័យរបស់និស្សិតក្នុងការកែប្រែពិភពលោក , ហើយ**បំពេញ** (ផ្តល់ជូន)នូវការត្រៀមឱ្យមានការសិក្សាអប់រំ ដោយធ្វើការអភិវឌ្ឍន៏ឱ្យបានសកម្មនូវប្រព័ន្ធសាលា រួមមានកសាងបន្ទប់រៀន ការផលិតកម្មវិធីផ្តល់នូវសម្ភារះបង្រៀន បណ្តុះបណ្តាលគ្រូ និងជូនប្រាក់បៀវត្សក្នុងស្រុកឱ្យបានប្រសើរ ។

៥១- ដូចបានពិនិត្យរួចមកហើយ កាតព្វកិច្ចរបស់រដ្ឋភាគីចំពោះវស័យសិក្សាអប់រំផ្នែកបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងការសិក្សាគ្រឹះ គឺមិនដូចគ្នាទេ ។ ដូចបានជូនអត្ថន័យនៃមាត្រា ១៣(២) រដ្ឋភាគីត្រូវមានកាតព្វកិច្ចផ្តល់អាទិភាពឱ្យបញ្ចូននូវការខានមិនបាន ការសិក្សាផ្នែកមធ្យមសិក្សាដោយឥតគិតថ្លៃ ។ ការបកស្រាយនូវមាត្រា ១៣(២) ត្រូវបានពង្រឹងឱ្យមានអាទិភាពយល់ព្រមជូនដល់ការសិក្សាផ្នែកបឋមសិក្សា ដូចចែងក្នុងមាត្រា ១៤ ។ កាតព្វកិច្ចផ្តល់ជូនសិក្សាផ្នែកបឋមសិក្សា សំរាប់ជនទាំងអស់ គឺជាភារកិច្ចភ្លាមៗ សំរាប់រដ្ឋភាគីទាំងអស់ ។

៥២- ចំពោះមាត្រា ១៣(២) ខ-ឃ, រដ្ឋភាគីមានកាតព្វកិច្ចភ្លាមៗ ដើម្បី "បោះដំណើរទៅមុខ" (មាត្រា ២ [១]) ឆ្ពោះទៅរកការសំរេចផលនូវការសិក្សាអប់រំផ្នែកមធ្យមសិក្សា ឧត្តមសិក្សា និងការសិក្សាគ្រឹះ សំរាប់ជនទូទៅ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួន ។ ទោះក្នុងកំរិតអប្បរិមាក្តី រដ្ឋភាគីត្រូវបានតម្រូវឱ្យជ្រើសរើស និងអនុវត្តយុទ្ធសាស្ត្រអប់រំជាតិដែលរួមមានការផ្តល់ជូននូវការសិក្សាអប់រំផ្នែកមធ្យមសិក្សា ឧត្តមសិក្សា និងការសិក្សាគ្រឹះស្របតាមកិច្ចព្រមព្រៀង ។ យុទ្ធសាស្ត្រនេះត្រូវមាន យន្តការ ដូចជា ចំនុចសំគាល់ និងកំរិតមួយដែលអាចចំណាំបានទៅលើសិទ្ធិទទួលការសិក្សាអប់រំ ហើយដោយយន្តការនេះហើយ ដែលការរីកចំរើនអាចនាំឱ្យមានការកត់ត្រាដោយជិតស្និទ្ធបាន ។

៥៣- ក្រោមប្រការ ១៣(២ ង រដ្ឋភាគីត្រូវមានសមត្ថភាពឱ្យធានាថា ប្រព័ន្ធរៀនសូត្របន្ត គឺជាកន្លែងមួយដើម្បីជួយដល់ជនដែលក្រីក្រជាងគេ ។ កាតព្វកិច្ចតាមដានដ៏សកម្មនូវ "ការអភិវឌ្ឍន៍ប្រព័ន្ធសាលានូវរាល់កំរិត" គឺពង្រឹងនូវភាពទទួលខុសត្រូវយ៉ាងសំខាន់របស់ភាគី ដើម្បីធានាថា ការផ្តល់ដោយផ្ទាល់នូវសិទ្ធិទទួលការសិក្សាអប់រំគ្រប់កាលៈទេសៈ ។

៥៤- រដ្ឋភាគី ត្រូវមានកាតព្វកិច្ចដើម្បីកសាង "ស្តង់ដារអប់រំអប្បរិមា" ដែលក្នុងស្តង់ដារនេះរាល់ស្ថាប័នអប់រំទាំងអស់ដែលបានរៀបចំឡើងត្រូវស្របតាមមាត្រា ១៣(៣) និង (៤) ។ រដ្ឋភាគីត្រូវតែរក្សាឱ្យមានតម្លាភាព និងប្រព័ន្ធប្រសិទ្ធភាព ដើម្បីកត់ត្រាស្តង់ដារនោះ ។ រដ្ឋភាគីពុំមានកាតព្វកិច្ចផ្តល់មូលធនដល់ស្ថាប័ន ដែលកសាងឡើងស្របតាមមាត្រា ១៣ (៣) និង (៤) ទេ ។ ទោះយ៉ាងណាក្តី ប្រសិនបើរដ្ឋមួយជ្រើសរើសធ្វើវិភាគទានហិរញ្ញវត្ថុដល់ស្ថាប័នអប់រំឯកជន គេអាចធ្វើបានដោយគ្មានរើសអើងទោះទៅលើមូលដ្ឋានដែលបានហាមឃាត់ក្តី ។

៥៥- រដ្ឋភាគីមានកាតព្វកិច្ចធានាថា សហគមន៍ និងគ្រួសារទាំងឡាយ មិនពឹងផ្អែកលើពលកម្មកុមារ ។ គណៈកម្មាធិការបញ្ជាក់ពិសេសពីសារន្តនៃការសិក្សាអប់រំដោយបានលប់បំបាត់ពលកម្មកុមារ ហើយនឹងកាតព្វកិច្ចដូចចែងក្នុងមាត្រា ៧(២) នៃអនុសញ្ញា (១៩៩៩) នៃបែបបទដ៏អាក្រក់របស់ពលកម្មកុមាររបស់អង្គការ ILO ។ លើសនេះទៀត តាមមាត្រា ២(២) រដ្ឋភាគីត្រូវមានកាតព្វកិច្ចដកហូតនូវភេទ និងរបស់ដទៃទៀតដែលគេបានសន្មត់ថា ជាតួយ៉ាងនៃអ្វីមួយដែលធ្វើឱ្យរាំងស្ទះដល់ការចូលសិក្សារបស់នារី ស្ត្រី និងក្រុមជនក្រីក្រងទៀត ។

៥៦- នៅក្នុងយោបល់ទូទៅទី ៣, គណៈកម្មាធិការបានទាញការយកចិត្តទុកដាក់ចំពោះកាតព្វកិច្ចនៃរដ្ឋភាគីឱ្យចាប់ដំណើរការអំពី "ការឧបត្ថម្ភ និងសហប្រតិបត្តិការដោយបុគ្គល និងតាមរយៈជាអន្តរជាតិ ជាពិសេសផ្នែកសេដ្ឋកិច្ច និងបច្ចេកទេសឱ្យឆ្ពោះទៅរកការសំរេចទាំងស្រុងនូវសិទ្ធិដែលបានទទួលស្គាល់ក្នុងកិច្ចព្រមព្រៀង ដូចជា សិទ្ធិទទួលការសិក្សាអប់រំមាត្រា ២(១) និង ២៣ នៃកិច្ចព្រមព្រៀង , មាត្រា ៥៦ នៃកត្តិកាសញ្ញាអង្គការសហប្រជាជាតិមាត្រា ១០ នៃសេចក្តីប្រកាសសកល នូវការសិក្សាសំរាប់ជនទូទៅ, និងវាក្យខ័ណ្ឌ ៣៤ តែសេចក្តីប្រកាសទីក្រុងវីយែន និងកម្មវិធីសកម្មភាព, ទាំងអស់នេះបានពង្រឹងកាតព្វកិច្ចរដ្ឋភាគីដែលប្រកាសនៅទីក្រុងវីយែន និងកម្មវិធីសកម្មភាព, ទាំងអស់នេះបានពង្រឹងកាតព្វកិច្ចរដ្ឋភាគីចំពោះការផ្តល់នូវការឧត្ថម្ភ និងសហប្រតិបត្តិការអន្តរជាតិ ចំពោះការធ្វើឱ្យបានសំរេចនូវសិទ្ធិទទួលការសិក្សាអប់រំ ។ ចំពោះការចរចា និងការធ្វើសច្ចាប័នលើកិច្ចព្រមព្រៀងអន្តរជាតិ រដ្ឋភាគីគួរតែចាប់ដំណើរការដើម្បីធានាថា ឯកសារទាំងនោះមិនជះឥទ្ធិពលប្រឆាំងនឹងសិទ្ធិទទួលការសិក្សាអប់រំឡើយ ។ ស្រដៀងគ្នានេះ រដ្ឋភាគីមានកាតព្វកិច្ចធានាថា សកម្មភាពរបស់គេជាសមាជិកនៃស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ មានសិទ្ធិត្រឹមត្រូវលើសិទ្ធិទទួលការសិក្សាអប់រំ ។

៥៧- នៅក្នុងយោបល់ទូទៅទី ៣ គណៈកម្មាធិការបញ្ជាក់ថា រដ្ឋភាគីមាន "កាតព្វកិច្ចសំខាន់អប្បរិមា ដើម្បីធានាការពេញចិត្ត, ដែលយ៉ាងហេតុណាស់, ឱ្យមានកំរិតសំខាន់ជាអប្បរិមាដែរ" ចំពោះសិទ្ធិនិមួយៗ ដែលបានរៀបរាប់នៅក្នុងកិច្ចព្រមព្រៀង

រួមមាន "ទ្រង់ទ្រាយជាមូលដ្ឋានបំផុតនៃការសិក្សាអប់រំ" ។ នៅក្នុងខ្លឹមសារនៃមាត្រា ១៣ ខ្លឹមសារស្នូលនេះ រួមមាន កាតព្វកិច្ច : ដើម្បីធានាសិទ្ធិអាចចូលរៀនបាននៅក្នុងស្ថាប័នអប់រំសាធារណៈ និងកម្មវិធីដែលជាមូលដ្ឋាននៃការមិនរើសអើង, ដើម្បីធានាផ្តល់ការសិក្សាឱ្យស្របតាមកម្មវត្ថុដូចមានចែងនៅក្នុងមាត្រា ១៣(១) , ដើម្បីផ្តល់ការសិក្សាផ្នែកបឋមសិក្សាដល់ជនគ្រប់រូប ឱ្យស្របតាមមាត្រា ១៣(២) ក , ដើម្បីជ្រើសរើស និង អនុវត្តន៍យុទ្ធសាស្ត្រអប់រំជាតិ ដែលរួមមាន ការផ្តល់ការសិក្សាផ្នែកមធ្យមសិក្សា, ឧត្តមសិក្សា និងការសិក្សាគ្រឹះ, ហើយ ដើម្បីធានាដល់ការជ្រើសរើសការសិក្សាដោយសេរី ដោយគ្មានការរំខានពីរដ្ឋ និងពីភាគីទី ៣ , ដោយធ្វើឱ្យស្របតាម "ស្តង់ដារអប់រំអប្បបរិមា" (មាត្រា ១៣ (៣) និង (៤) ។

## ការរំលោភ

៥៨- នៅពេលដែលមាតិការស្របតាមមាត្រា ១៣ (ផ្នែកទី I) នេះ អនុវត្តចំពោះកាតព្វកិច្ចទូទៅ និងពិសេសរបស់រដ្ឋភាគី ហើយ (ផ្នែកទី II), ដំណើរការដ៏មានថាមពលនឹងត្រូវរៀបចំជាចលនា ដែលសំរួលដល់ការធ្វើអត្តសញ្ញាណចំពោះការរំលោភសិទ្ធិទទួលការសិក្សាអប់រំ។ ការរំលោភលើមាត្រា ១៣ អាចកើតមានឡើងតាមរយៈសកម្មភាពផ្ទាល់របស់ភាគី (អំពើដែលបានប្រព្រឹត្តឡើង) ឬតាមរយៈការខកខានរបស់គេ ក្នុងការចាប់ដំណើរការដែលបានតម្រូវដោយកិច្ចព្រមព្រៀង (អំពើដែលគេបានភ្លេច/ខកខានធ្វើ) ។

៥៩- តាមមធ្យោបាយនៃរូបភាព, ការរំលោភលើមាត្រា ១៣ រួមមាន : ការបញ្ចូល ឬ ការខកខានមិនបានដកចេញនូវច្បាប់ដែលរើសអើងដល់ឯកត្តជន ឬ ក្រុមនានា ទោះក្នុងមូលដ្ឋានហាមឃាត់ណាមួយក្តី, នៅក្នុងវិស័យអប់រំ, ការខកខានចាត់វិធានការណ៍ដែលសំដែងពីអំពើនៃការរើសអើងផ្នែកសិក្សាអប់រំ, ការប្រើនូវកម្មវិធីសិក្សាដែលមិនមាននិរន្តភាពទៅនឹងការសិក្សាអប់រំ, កម្មវត្ថុទាំងឡាយដែលចែងនៅក្នុងមាត្រា ១៣ (១), ការខកខានមិនបានរក្សានូវតម្លាភាព និងប្រព័ន្ធដែលមានប្រសិទ្ធភាព ដើម្បីកំណត់ការត្រួតពិនិត្យឱ្យស្របតាមមាត្រា ១៣(១), ការខកខានមិនបានណែនាំ , ដែលបានចាត់ទុកជាកិច្ចការអាទិភាព, កាសិក្សាផ្នែកបឋមសិក្សាដែលត្រូវតែខកខានមិនបាននឹងមានឱ្យដោយឥតគិតថ្លៃដល់ជនគ្រប់រូប, ការខកខានមិនបានធ្វើការ "គិតទុកជាមុន, ឱ្យចេញជារូបរាង និងមានទិសដៅ" ច្បាស់លាស់ឈានទៅរកការសំរេចដ៏ប្រសើរទៅដល់ការសិក្សាអប់រំផ្នែកមធ្យមសិក្សា ឧត្តមសិក្សា និងការសិក្សាគ្រឹះ ដើម្បីឱ្យសមស្របតាម មាត្រា ១៣ (២) ២-ឃ, ការហាមឃាត់មិនឱ្យមានស្ថាប័នអប់រំឯកជន, ការខកខាននានាលើស្ថាប័នអប់រំឯកជនដែលស្របទៅនឹង "ស្តង់ដារអប់រំអប្បបរិមា ដែលបានតម្រូវដោយមាត្រា ១៣ (៣) និង (៤) , ការបដិសេធន៍នូវសេរីភាពនៃការសិក្សារបស់បុគ្គលិក និងនិស្សិត, ការបិទស្ថាប័នអប់រំនៅពេលមានភាពតានតឹងផ្នែកនយោបាយ ដែលជាការមួយមិនស្របនឹងមាត្រា ៤ ។

## III. ភាតព្វកិច្ចនៃអ្នកប្រព្រឹត្ត ក្រៅពីរដ្ឋភាគី

៦០- ចំពោះមាត្រា ២២ នៃកិច្ចព្រមព្រៀង តួនាទីរបស់ភ្នាក់ងារអង្គការសហប្រជាជាតិ រួមមាន កំរិតថ្នាក់ប្រទេសតាមរយៈការអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ក្នុងការឧបត្ថម្ភដល់កំលាំងការងារ (UNDAF) ដែលជាសារវន្តដ៏ពិសេសដល់ការធ្វើឱ្យបានសំរេចមាត្រា ១៣ ។ ការប្រមូលផ្តុំនូវការខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យសំរេចនូវសិទ្ធិទទួលការសិក្សាអប់រំគួរតែត្រូវថែរក្សា ដើម្បីកែលំអភាពជិតសិទ្ធ និងអន្តរសកម្មភាព ក្នុងចំណោមអ្នកប្រព្រឹត្តដែលពាក់ព័ន្ធទាំងអស់ រួមមានសមាសភាពនានានៃសង្គមស៊ីវិល ។ អង្គការ UNESCO អង្គការអភិវឌ្ឍន៍កម្មវិធីអង្គការសហប្រជាជាតិ UNDP, អង្គការ UNICEF អង្គការការងារអន្តរជាតិ ILO, ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍ភូមិភាគ, IMF និងអង្គភាពពាក់ព័ន្ធដទៃទៀតក្នុងរង្វង់ប្រព័ន្ធអង្គការសហប្រជាជាតិ, គួរតែកែលំអសហប្រតិបត្តិការរបស់គេក្នុងការអនុវត្តនូវសិទ្ធិទទួលការសិក្សាអប់រំគ្រប់កំរិតជាតិ ដោយគោរពឱ្យបានត្រឹមត្រូវនូវអាណត្តិពិសេសរបស់គេ, ហើយកសាងជំនាញរបស់គេរៀងៗខ្លួន ។ ដោយឡែក ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ជាពិសេសធនាគាពិលោក និង IMF គួរតែចាប់អារម្មណ៍ខ្ពស់ចំពោះការការពារសិទ្ធិទទួលការសិក្សារៀនសូត្រ អំពីគោលនយោបាយឱ្យខ្ចីទុន, កិច្ចព្រមព្រៀងឥណទាន កម្មវិធីកែសំរួលរចនាសម្ព័ន្ធ និងចាត់ចែងមធ្យោបាយឆ្លើយតបទៅនឹងវិបត្តិបំណុល ។ ពេលពិនិត្យមើលរបាយការណ៍របស់រដ្ឋភាគី គណៈកម្មាធិការនឹងពិចារណាអំពីផលនៃការឧបត្ថម្ភ ដែលផ្តល់ដោយអ្នកប្រព្រឹត្តជាជាងរដ្ឋភាគីទៅតាមសមត្ថភាពរបស់រដ្ឋ ដើម្បីតម្រូវតាមកាតព្វកិច្ចក្រោមមាត្រា ១៣ ។ ការជ្រើសរើសនូវមូលដ្ឋានដោះស្រាយបញ្ហាសិទ្ធិមនុស្ស ដោយភ្នាក់ងារជំនាញអង្គការសហប្រជាជាតិ, កម្មវិធី និងអង្គភាព អង្គការសហប្រជាជាតិដទៃទៀត, ដែលនឹងត្រូវសំរួលឱ្យបានធំធេងនូវការអនុវត្តន៍សិទ្ធិទទួលការសិក្សាអប់រំនេះ ។